# ក្នុងជំនួបពិភាក្សារវាងឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយលោក Ramesh Subramaniam អគ្គនាយកនៃធនាគារអភិវឌ្ឍន៍អាស៊ី ADB ប្រចាំតំបន់អាស៊ីអាគ្នេយ៍



នៅព្រឹកថ្ងៃពុធ ០៥រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ នៅទីស្តីការក្រសួង ជាដៃគូពិភាក្សា បានផ្តោតការយកចិត្តទុកដាក់ជាសំខាន់ ទៅលើដំណើរការអនុវត្តគម្រោងហិរញ្ញប្បទានឥណទានសម្បទានរបស់ ADB ដែលត្រូវធ្វើរួមគ្នាជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រាប់អភិវឌ្ឍន៍វិស័យទឹកស្អាតនៅទីប្រជុំជនក្នុងប្រទេសកម្ពុជា ។



ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាព នៃការអនុវត្តគម្រោងរួមគ្នា រវាង ក្រសួង និង ADB ដែលផ្តោតសំខាន់ទៅលើការកែលំអរជួសជុល និងកសាង ប្រព័ន្ធប្រព្រឹត្តិកម្ម ក៏ដូចជាប្រព័ន្ធចែកចាយទឹកស្អាតនៅតាមបណ្តាអង្គភាពសាធារណៈមួយចំនួន រួមទាំងប្រព័ន្ធអនាម័យផងដែរ ។




ឆ្លៀតឱកាសនោះ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានលើកឡើងពីទស្សនៈវិស័យរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម គឺការលើកទឹកចិត្តអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេស ឲ្យមកបណ្តាក់ទុនលើវិស័យទឹកស្អាត ជាលក្ខណៈទ្រង់ទ្រាយធំ ហើយអាចធ្វើការលក់ដុំ ទៅអ្នកចែកចាយបន្ត ក្នុងតម្លៃមួយ សមរម្យដែលអាចទទួលយកបានទាំងអស់គ្នា ។ ពីព្រោះក្រសួងកំពុងផ្តោតការផ្គត់ផ្គង់ទឹកស្អាតមិនត្រឹម តែក្នុងតំបន់ទីក្រុង និងទីប្រជុំជនទេ តែត្រូវយកចិត្តទុកដាក់ដល់ទីជនបទ តាមលទ្ធភាពជាក់ស្តែងផងដែរ ។ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី ក៏បានជម្រុញផងដែរឲ្យពន្លឿនការងារខ្លះដែល នៅសេសសល់ក្នុងគម្រោងអភិវឌ្ឍន៍រួមគ្នានោះ មានដូចជា ការពន្លឿនការជ្រើសរើសទីប្រឹក្សា បច្ចេកទេស និងការងារលទ្ធកម្មជាដើម ។ ជាមួយគ្នានេះ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតនៅតែចាត់ទុកការបណ្តុះបណ្តាលធនធានមនុស្សជាកត្តាសំខាន់ និងស្នើដល់ ADB បន្តជួយថែមទៀតលើការងារនេះ ជាពិសេសជំនាញគ្រប់គ្រងគម្រោង និងជំនាញត្រួតពិនិត្យក្រោយអនុវត្តគម្រោងជាដើម ។ ហើយចាប់ពីពេលនេះតទៅ យើងត្រូវកំណត់ពេលវេលាជួបគ្នាជាប្រចាំក្នុងកំរិតជំនាញដើម្បីពិភាក្សាស្តាប់របាយការណ៍ និងពិនិត្យវាយតម្លៃពីលទ្ធផល និងភាពប្រឈម នៃការអនុវត្តគម្រោងរួមគ្នានេះ ។



លោក Ramesh Subramaniam អគ្គនាយក នៃធនាគារអភិវឌ្ឍន៍អាស៊ី ADB ប្រចាំតំបន់អាស៊ីអាគ្នេយ៍ បានលើកឡើង ពីយុទ្ធសាស្រ្ត ដៃគូក្នុងប្រទេសរបស់កម្ពុជា (CPS) ពីឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៣ ដែលនឹងផ្តល់នូវក្របខ័ណ្ឌគាំទ្ររបស់ADB ចំពោះកម្ពុជា ដោយធ្វើសុខដុមនីយកម្មជាមួយ យុទ្ធសាស្រ្តចតុកោណនៃរាជ រដ្ឋាភិបាលកម្ពុជា និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ។ ចំពោះមុខ ADB មានការ យកចិត្តទុកដាក់ខ្ពស់សម្រាប់វិស័យទឹកស្អាត និងអនាម័យ នៅកម្ពុជា ព្រមទាំងគាំទ្រនូវទស្សនៈវិស័យរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងនោះការ បណ្តុះបណ្តាលធនធានមនុស្ស គឺជាកត្តាអាទិភាពដែលយើងត្រូវយកចិត្តទុកដាក់ ។

